# ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS

Khmer | ភាសាខ្មែរ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS ពណ៌នាអំពីឥរិយាបថ ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលទទួលបានមូលនិធិក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ និងជាក់ស្តែងមួយចំនួននៃអាកប្បកិរិយាដែលបង្ហាញពីសមត្ថភាពរបស់បុគ្គលិក និងបង្កើតភាសារួមមួយអំពី 'អ្វីដែលល្អមើលទៅមានលក្ខណៈដូចម្តេចដែរ'។ ក្របខ័ណ្ឌនេះត្រូវបានគាំទ្រដោយឧបករណ៍ និងសៀវភៅមគ្គុទ្ទេសក៍នានាដើម្បីជួយអ្នកផ្តល់សេវា បុគ្គលិក និងអ្នកចូលរួមជាមួយនឹងការរៀបចំផែនការ និងការគ្រប់គ្រងកម្លាំងពលកម្ម ការជ្រើសរើសបុគ្គលិក និងអាជីពនៅក្នុងវិស័យនេះ។

## អ្វីដែលនឹងរំពឹងទុក៖

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្មជំរុញនាំអ្នកឱ្យធ្វើជាជំហានៗតាមរយៈជំនាញ និងចំណេះដឹងរបស់បុគ្គលិកនៅគ្រប់កម្រិតទាំងអស់ដែលគួរតែមានដើម្បីគាំទ្រដល់អ្នកចូលរួម NDIS។

អ្នកជ្រើសរើសកម្រិតនៃការងារដែលអ្នកចង់ដឹង និងជំនួយឯកទេស ឬការគាំទ្រជាក់លាក់ណាមួយ ឧទាហរណ៍ ការឆ្លើយតបទៅនឹងវប្បធម៌ ការអនុវត្តការគ្រប់គ្រងម៉ោងបរិភោគអាហារ ឬការសម្របសម្រួលការគាំទ្រ។ ជ្រើសរើសចេញពីប្រភេទនៃសមត្ថភាពរបស់បុគ្គលិកចំនួនបីយ៉ាងទូលំទូលាយ (ទូទៅ កម្រិតខ្ពស់ ជំនួយ) ឬអ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកគ្រប់គ្រងជួរមុខ ដើម្បីមើលសមត្ថភាពស្នូលនានា។ អ្នកនឹងរកឃើញសូចនាករផ្នែកអាកប្បកិរិយានៅក្នុងបញ្ជីទម្លាក់ចុះសម្រាប់សមត្ថភាពនីមួយៗ និងចំណេះដឹងសំខាន់ៗសម្រាប់សមត្ថភាពដែលផ្គូបផ្គង។

## *សមត្ថភាពគំរូ - ប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ខ្ញុំ*

ឧទាហរណ៍នៃសូចនាករផ្នែកអាកប្បកិរិយា៖

- *សុំការអនុញ្ញាតពីខ្ញុំ មុនពេលអ្នកចូលមកក្នុងចន្លោះគម្លាតផ្ទាល់ខ្លួនរបស់ខ្ញុំ ឬប៉ះខ្ញុំ។ សូមគោរពការឆ្លើយតបរបស់ខ្ញុំ ហើយចងចាំថាអ្នកគឺជាភ្ញៀវនៅពេលដែលនៅក្នុងផ្ទះរបស់ខ្ញុំ ឬកន្លែងសហគមន៍របស់ខ្ញុំ។*
- *គោរពសិទ្ធិឯកជនភាពរបស់ខ្ញុំ។ សុំការអនុញ្ញាតពីខ្ញុំមុននឹងប្រមូល ប្រើប្រាស់ ឬលាតត្រដាងព័ត៌មានអំពីខ្ញុំ។*

# ក្របខ័ណ្ឌក្នុងការអនុវត្ត៖

**អ្នកចូលរួម៖** Vinay សប្បាយចិត្តជាមួយបុគ្គលិករបស់គាត់ឈ្មោះ Amy ហើយមានអារម្មណ៍ថាពួកគេប្រាស្រ័យទាក់ទងបានល្អ ទោះជាយ៉ាងណាក៏ដោយ គាត់មានអារម្មណ៍ថាមានផ្នែកខ្លះដែលឯកជនភាពរបស់គាត់មិនត្រូវបានគេគោរព។ គាត់ចង់ស្វែងយល់ពីរបៀបដែលគាត់អាចផ្តល់មតិកែលម្អនេះដល់ Amy និងភាសាមួយចំនួនដែលអាចប្រើបានល្អបំផុត។ Vinay ប្រើ **ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម** ដើម្បីពិនិត្យមើលសមត្ថភាពដែលបុគ្គលិករបស់គាត់ដែលគួរតែបង្ហាញ។ គាត់រកឃើញវត្ថុបំណង 'ទំនាក់ទំនងរបស់យើង' និង 'ប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ខ្ញុំ' ហើយអានថា 'សុំការអនុញ្ញាតពីខ្ញុំ មុនពេលអ្នកចូលមកក្នុងចន្លោះគម្លាតផ្ទាល់ខ្លួនរបស់ខ្ញុំ ឬប៉ះខ្ញុំ។ សូមគោរពការឆ្លើយតបរបស់ខ្ញុំ ហើយចងចាំថាអ្នកគឺជាភ្ញៀវនៅពេលនៅក្នុងផ្ទះរបស់ខ្ញុំ ឬកន្លែងសហគមន៍របស់ខ្ញុំ'។

Vinay សម្រេចចិត្តនិយាយជាមួយអ្នកផ្តល់សេវារបស់គាត់ ហើយចែករំលែកក្របខ័ណ្ឌនោះដើម្បីរំលេចឱ្យឃើញថាគាត់ចង់ឱ្យ Amy ឬបុគ្គលិកផ្សេងទៀតសួរមុនពេលពួកគេចូលទៅក្នុងបន្ទប់ ឬបន្ទប់ទឹករបស់គាត់។ Vinay និយាយថា គាត់ពិតជាចូលចិត្តវិធីដែល Amy ប្រាស្រ័យទាក់ទងជាមួយគាត់ ហើយថានាងកំពុងធ្វើការងារដ៏អស្ចារ្យនៅក្នុងគ្រប់វិស័យផ្សេងទៀត គាត់គ្រាន់តែត្រូវការឱ្យនាងចងចាំថា ឯកជនភាពរបស់គាត់គឺសំខាន់។

**អ្នកផ្តត់ផ្គង់៖** Local Supports Inc. មានបំណងចង់ពង្រឹងសមត្ថភាពរបស់បុគ្គលិកពួកគេ និងធានាថាបុគ្គលិករបស់ពួកគេយល់ដឹងពីអ្វីដែលពួកគេត្រូវបានរំពឹងទុក។ ពួកគេនិយាយជាមួយបុគ្គលិកអំពីសមត្ថភាពសម្រាប់ប្រភេទការងារផ្សេងៗគ្នា៖ ការគាំទ្រទូទៅ ការគាំទ្រកម្រិតខ្ពស់ ជំនួយបន្ទាប់បន្សំ ការមើលខុសត្រូវ និងការគ្រប់គ្រងជួរមុខ ការគ្រប់គ្រងជាន់ខ្ពស់ និងភាពជាអ្នកដឹកនាំ។ ពួកគេនិយាយជាមួយក្រុមនីមួយៗអំពីរបៀបដែលសមត្ថភាពនានាត្រូវអនុវត្តចំពោះការងាររបស់ពួកគេ ហើយសង្កត់ធ្ងន់លើសារៈសំខាន់នៃសមត្ថភាពបន្ថែមមួយចំនួនដូចជា ការឆ្លើយតបទៅនឹងអត្តសញ្ញាណវប្បធម៌ជាផ្នែកមួយដែលពួកគេចង់កែលម្អ។ អ្នកមើលការខុសត្រូវប្រើប្រាស់សមត្ថភាពនានាដើម្បីគាំទ្រពួកគេនៅពេលនិយាយជាមួយបុគ្គលិកដែលពួកគេគាំទ្រអំពីតួនាទីរបស់ពួកគេ និងពិភាក្សាអំពីការគាំទ្រដែលពួកគេត្រូវការដើម្បីសម្រេចបាន។

Local Supports ក៏កំពុងប្រើប្រាស់ **ឧបករណ៍បង្កើតការពណ៌នាមុខតំណែង** និង **សៀវភៅមគ្គុទ្ទេសក៍សម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក** ដើម្បីកែលម្អការលៃតម្រូវរវាងបុគ្គលិកដែលពួកគេជ្រើសរើស និងគុណតម្លៃ និងគោលដៅនានារបស់អង្គការ។ ការនេះកំពុងកែលម្អគុណភាព និងភាពស៊ីសង្វាក់នៃការគាំទ្រដែលពួកគេផ្តល់ និងកាត់បន្ថយចំនួនផ្លាស់ប្តូរកម្លាំងពលកម្ម។

## ព័ត៌មានសំខាន់ៗ៖

ក្របខ័ណ្ឌ៖

- ត្រូវបានសរសេរចេញពីទស្សនៈរបស់អ្នកចូលរួម NDIS។
- បកប្រែក្រមប្រតិបត្តិ និងស្តង់ដារអនុវត្តន៍ NDIS ទៅជាអាកប្បកិរិយា និងសមត្ថភាពដែលអាចសង្កេតបានសម្រាប់បុគ្គលិកនៅគ្រប់កម្រិតទាំងអស់។
- ពណ៌នាអំពីឥរិយាបថ ជំនាញ និងចំណេះដឹង (សមត្ថភាព) ដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ ដោយផ្តោតខ្លាំងលើការប្រាស្រ័យទាក់ទង និងអន្តរកម្មរវាងបុគ្គលិក និងអ្នកចូលរួម។
- ពណ៌នាអំពី 'អ្វីដែលល្អមើលទៅមានលក្ខណៈដូចម្តេចដែរ' នៅពេលប្រកាន់ខ្ជាប់នូវគុណតម្លៃដែលផ្អែកលើសិទ្ធិរបស់ NDIS ដើម្បីជំរុញការផ្លាស់ប្តូរវប្បធម៌ជាវិជ្ជមាន។
- ពាក់ព័ន្ធនឹងបុគ្គលិកទាំងអស់ដែលផ្តល់សេវា និងការគាំទ្រដែលបានផ្តល់មូលនិធិដោយ NDIS ដល់អ្នកចូលរួមនានា៖
  - ការងារគាំទ្រផ្ទាល់ខ្លួនប្រចាំថ្ងៃ (ដូចជាជំនួយលើការងារប្រចាំថ្ងៃ ឬការថែទាំផ្ទាល់ខ្លួន)
  - ការគាំទ្រឯកទេស ការគាំទ្រការកសាងសមត្ថភាព (ដូចជាការគាំទ្រផ្នែកសុខភាព និងការព្យាបាល)
  - អ្នកដឹកនាំ និងអ្នកគ្រប់គ្រង និង
  - សេវាកម្មជំនួយបន្ទាប់បន្សំ (ដូចជាការថែទាំ ការសម្អាត ឬទទួលភ្ញៀវ)។
- បានរចនាឡើងសម្រាប់អ្នកណាម្នាក់ដែលត្រូវការយល់ដឹង ណែនាំ ឬចូលរួមនៅក្នុងកម្លាំងពលកម្ម NDIS។

## ការចូលប្រើ និងការប្រើប្រាស់ក្របខ័ណ្ឌ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្មមាននៅតាមអនឡាញ និងជាសណ្ឋាន PDF ដែលអាចទាញយកបាន។ ក្របខណ្ឌ | សមត្ថភាពកម្លាំងពលកម្ម NDIS (ndiscommission.gov.au)

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម ឬការអនុវត្តរបស់វា សូមចូលមើលគេហទំព័រ៖ https://workforcecapability.ndiscommission.gov.au/។

**ទំនាក់ទំនងគម្រោង៖** contactcentre@ndiscommission.gov.au ឬ 1800 035 554។